ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:..៣១៨៧.សជណ.ប.ស្ក ក/ហប

ថ្ងៃ ចន្ទ ២ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២៣

**ជម្រាបជូន**
**លោកប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ខេ2អេ មេនេចម៉ិន ឯ.ក**

**កម្មវត្ថុ ៖** ករណីសំណើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សា សម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ក្រុមហ៊ុន ខេ2អេ មេនេចម៉ិន ឯ.ក។

**យោង ៖**
- ពាក្យស្នើសុំចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន ខេ2អេ មេនេចម៉ិន ឯ.ក
- របាយការណ៍ចុះពិនិត្យទីតាំង ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣ របស់មន្ត្រីជំនាញនាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន
- វិញ្ញាបនបត្រលេខMOC-៤៥៨៦៦៣៣៨ ពណ.ចបព ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ របស់ក្រសួងពាណិជ្ជកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោកប្រធាន** ជ្រាបថា ក្រសួងបរិស្ថានឯកភាពលើសំណើសុំចុះបញ្ជីជាក្រុមហ៊ុនទីប្រឹក្សា សម្រាប់ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម របស់ក្រុមហ៊ុន ខេ2អេ មេនេចម៉ិន ឯ.ក ដែលមានការិយាល័យស្ថិតនៅផ្ទះលេខ៤១ ផ្លូវលេខ៣៦០ ភូមិ៧ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ តំណាងដោយលោក ទែន រ៉ា សញ្ជាតិខ្មែរ មុខរបរពាណិជ្ជករ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០៩០៨៦៨២៦៥ ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៧ ជាប្រធានក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ដោយលោកប្រធានត្រូវគោរព និងអនុវត្តតាមកិច្ចសន្យាការពារបរិស្ថានចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ របស់ក្រុមហ៊ុន។

លិខិតឯកភាពលើការចុះបញ្ជីនេះ ផុតសុពលភាពត្រឹមថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៤។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** អនុវត្ត និងចាត់ចែងតាមការគួរ។

សូម **លោកប្រធាន** ទទួលនូវសេចក្តីរាប់អានដ៏ស្មោះពីខ្ញុំ៕

**ក.រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ធា ដុប**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ.វ.ក
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរបរិស្ថានរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ

អគារមរតកតេជោ ដីឡូត៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006